ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៣២៨ ហិកតា ស្ថិតនៅភូមិសាស្ត្រ ស្រុកសំរោង ខេត្តឧត្តរមានជ័យ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦.៣២៨ (ប្រាំមួយពាន់បីរយម្ភៃប្រាំបី) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម(អំពៅ) ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃស្ករអំពៅ ដូចមាននៅក្នុងផែនទី និងនិយាមការចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៩ របស់អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ដែលភ្ជាប់ជាមួយនឹងលិខិតលេខ ៩០ជនស/អវទ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារកាលប្បវត្តិ




| ក្បាលដី | ទំហំ គិតជាហិកតា |
|---|---|
| ក្រុមហ៊ុន អង្គរ ស៊ូហ្គើរ | |
| A01 | 5120.48 |
| A02 | 310.41 |
| A03 | 57.18 |
| A04 | 735.67 |
| A05 | 104.59 |
| សរុប | 6,328.33 |

**សញ្ញាសំគាល់**

- ដីជាកម្មវត្ថុ នៃដីសម្បទានសេដ្ឋកិច្ច
- ផ្លូវទំហំ ៣០ម៉ែត្រ
- ព្រែកធម្មជាតិទទឹង ២០០ម៉ែត្រ

- ផ្ទៃដីជាកម្មវត្ថុ នៃដីសម្បទានសេដ្ឋកិច្ច អង្គរ ស៊ូហ្គើរ : ទំហំ ៦.៣២៨,៣៣ ហិកតា

វាស់វែង និង គូរប្លង់ ... GPS ( Leica 500 )

**តារាងនិយាមការនៃចំណុចទីតាំងដី**

Projection UTM, zon 48 N Datum WGS 84

| ID | Northing | Easting | ID | Northing | Easting |
|---|---|---|---|---|---|
| ផ្នែក A01 | | | 21 | 1571450.300 | 361101.708 |
| 1 | 1575325.268 | 351574.163 | ផ្នែក A03 | | |
| 2 | 1575325.550 | 357315.188 | 30 | 1573974.862 | 363286.668 |
| 3 | 1571243.807 | 361088.246 | 31 | 1573952.724 | 363431.356 |
| 4 | 1571025.901 | 361074.040 | 32 | 1570369.307 | 364531.673 |
| 5 | 1569523.225 | 361890.406 | ផ្នែក A04 | | |
| 6 | 1569247.812 | 358567.968 | 22 | 1574023.456 | 362969.078 |
| 7 | 1570317.596 | 358580.774 | 23 | 1573981.474 | 363243.458 |
| 8 | 1570331.072 | 350440.643 | 24 | 1569956.116 | 364626.015 |
| 9 | 1570330.323 | 350207.568 | 25 | 1568309.734 | 364550.683 |
| 10 | 1570324.759 | 348476.067 | 26 | 1567789.760 | 363566.623 |
| 11 | 1572324.193 | 348462.934 | 27 | 1568012.318 | 363341.986 |
| 12 | 1572326.216 | 349572.985 | 28 | 1571225.615 | 362176.041 |
| 13 | 1574023.419 | 349578.178 | 29 | 1572174.026 | 363276.359 |
| 14 | 1574028.689 | 351574.837 | ផ្នែក A05 | | |
| 15 | 1574325.678 | 351576.096 | 33 | 1567685.961 | 363370.181 |
| ផ្នែក A02 | | | 34 | 1567420.879 | 362868.508 |
| 16 | 1575325.567 | 357655.392 | 35 | 1566322.550 | 362862.979 |
| 17 | 1575325.646 | 359271.384 | 36 | 1566299.952 | 362376.405 |
| 18 | 1574321.442 | 359275.950 | 37 | 1568297.976 | 362382.353 |
| 19 | 1574154.025 | 360969.403 | 38 | 1568194.734 | 362656.235 |
| 20 | 1574123.714 | 361276.002 | | | |

351000 354500 358000 361500 365000

បានឃើញ និង ឯកភាព
ភ្នំពេញ.ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០៩
អគ្គនាយករដ្ឋបាលព្រៃឈើ និង ភូមិសាស្ត្រ
លឹម វ៉ាន់

បានពិនិត្យត្រឹមត្រូវ
ភ្នំពេញ.ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០០៩
ប្រធាននាយកដ្ឋានបច្ចេកទេស
ឡោ ជាមុន

ភ្នំពេញ.ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩
ប្រធានក្រុមវាស់វែង
ណុប សោភ័ណ